Labor

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ ៖..044....សកបយ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី 06 ខែ [illegible] ឆ្នាំ ១៩៩៩

## សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់បានជ្រាបថា ក្នុងពេលថ្មីៗនេះដោយសារការដាក់អោយកម្មករ និយោជិត ធ្វើការបន្ថែមម៉ោងច្រើនពេកនោះ បានបណ្តាលអោយមានគ្រោះថ្នាក់ការងារកើតឡើងជាបន្តបន្ទាប់។ ដើម្បីអនុវត្តមាត្រា ១៣៧ .មាត្រា ១៣៩ . និងមាត្រា ១៤១ នៃច្បាប់ស្តីពីការងារ ព្រមទាំងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ : ៨០ សកបយចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា អោយបានត្រឹមត្រូវនិងទទួលបានលទ្ធផលល្អប្រសើរសំដៅធានាបាននូវផលប្រយោជន៍របស់កម្មករ និយោជិត និង និយោជកនោះ សូមម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់អនុវត្តដូចតទៅ ៖-

១- ក្នុងករណីដែលរោងចក្រ សហគ្រាសមានការងារច្រើនខុសធម្មតាដែលតំរូវអោយមានការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ម្ចាស់ ឬនាយករោងចក្រសហគ្រាសត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាជាមុនសិន។ នៅពេលទទួលបានការអនុញ្ញាតទើប រោងចក្រ សហគ្រាសអាចរៀបចំធ្វើការបន្ថែមម៉ោងនេះបាន ។

២-ការរៀបចំធ្វើការបន្ថែមម៉ោងនេះត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពោលគឺម្ចាស់ ឬនាយករោងចក្រ សហគ្រាសមិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗចំពោះកម្មករ និយោជិតដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ ។

៣-ម្ចាស់ ឬនាយករោងចក្រ សហគ្រាសត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករ និយោជិតដូចតទៅ ៖-

ក-ស្មើនឹង ១៥០ភាគរយ ( ឬ១ដងកន្លះ ) នៃប្រាក់ឈ្នួលធ្វើការធម្មតាចំពោះការធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា ។

៣- ស្មើនឹង ២០០ភាគរយ (ឬ២ដង) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតាចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ (ពីម៉ោង ២២.០០ទៅម៉ោង៥.០០ព្រឹក)។

៤- ចំពោះរោងចក្រ សហគ្រាសដែលមានកម្មករនិយោជិតធ្វើការពេលយប់ ម្ចាស់ ឬនាយកសហគ្រាស ត្រូវតែផ្តល់ទីកន្លែងសំរាកទទួលទានដំណេករអោយបានសមរម្យដល់កម្មករ និយោជិតដែលចេញពីធ្វើការនៅពេលយប់ ពុំនោះសោតទេត្រូវផ្តល់មធ្យោបាយសំរាប់ដឹកជញ្ជូនកម្មករ និយោជិតទៅដល់លំនៅដ្ឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាពនៅពេលចប់ម៉ោងធ្វើការពេលយប់ ។

៥-ម្ចាស់រោងចក្រ សហគ្រាសត្រូវយកចិត្តទុកដាក់រៀបចំកន្លែងធ្វើការងាររបស់កម្មករ និយោជិតអោយមាន ខ្យល់អាកាសបរិបូរណ៍ រៀបចំសំភារៈវត្ថុធាតុដើមដែលមានឥទ្ធិពលប៉ះពាល់សុខភាពតាមរបៀបទុកដាក់ត្រឹមត្រូវ និងមានគិលានដ្ឋានប្រចាំ រោងចក្រ សហគ្រាស សំរាប់ការព្យាបាលបឋមដល់កម្មករនិយោជិត ។

ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា និងចាត់វិធានការពិន័យបំផុតទៅតាមច្បាប់ចំពោះ ម្ចាស់ឬនាយករោងចក្រសហគ្រាសកាត់ដេរណាដែលប្រព្រឹត្តល្មើសលើចំណុចដែលបានរៀបរាប់ខាងលើ នៃសេចក្តីជូនដំណឹងនេះព្រមទាំងប្រកាសនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កន្លងមក ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាមានក្តីសង្ឃឹមយ៉ាងមុតមាំថាម្ចាស់ និងនាយករោងចក្រសហគ្រាសកាត់ដេរទាំងអស់និងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរពុំខាន។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន</u>

-ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធិសភា

-អគ្គលេខាដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"

-ក្រសួងពត៌មាន" ដើម្បីផ្សព្វផ្សាយអោយបានទូលំទូលាយ"

-គ្រប់បណ្តាញវិទ្យុ ទូរទស្សន៍

-រាជកិច្ច

-គ្រប់អធិការដ្ឋានសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ខេត្ត-ក្រុង" ដើម្បីអនុវត្ត"

-បិទផ្សាយនៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

"នាយកដ្ឋានអធិការកិច្ចការងារ"

-កាលប្បវត្តិ និងឯកសារ